**ព្រះរាជាណាចក្រកម្ពុជា**
**ជាតិ សាសនា ព្រះមហាក្សត្រ**

**ក្រសួងអប់រំ យុវជន និងកីឡា**
**គណៈកម្មាធិការលទ្ធកម្ម**
លេខ : ១៦ អយក.គល.ទន

# សេចក្តីជូនដំណឹង
## ស្តីពីការអញ្ជើញចូលរួមដេញថ្លៃ
## ការផ្គត់ផ្គង់សម្ភារកីឡាគ្រប់ប្រភេទសម្រាប់ឆ្នាំ២០១៩ ថវិកាកម្មវិធី ឆ្នាំ២០១៩ ផ្នែកយុវជន និងកីឡា ជំពូក៦០ គណនី៦០០៥ អនុគណនី៦០០៥៣ របស់អង្គភាពថវិកាអគ្គនាយកដ្ឋានកីឡា

ក្រសួងអប់រំ យុវជន និងកីឡា សូមជូនដំណឹងដល់បណ្តាក្រុមហ៊ុន/សហគ្រាស (គិតទាំងសហគ្រាសឯកត្តបុគ្គល) ទាំងអស់ ដែលបានចុះបញ្ជីត្រឹមត្រូវក្នុងព្រះរាជាណាចក្រកម្ពុជាឱ្យបានជ្រាបថា ក្រសួងអប់រំ យុវជន និងកីឡា នឹងដាក់ឱ្យដេញថ្លៃជាសាធារណៈដើម្បីផ្គត់ផ្គង់សម្ភារកីឡាគ្រប់ប្រភេទសម្រាប់ឆ្នាំ២០១៩ ថវិកាកម្មវិធីឆ្នាំ២០១៩ ផ្នែកយុវជន និងកីឡា ជំពូក៦០ គណនី៦០០៥ អនុគណនី៦០០៥៣ កម្មវិធីទី៣.១.១ របស់អង្គភាពថវិកាអគ្គនាយកដ្ឋានកីឡា ។

កិច្ចលទ្ធកម្មនេះនឹងត្រូវបានធ្វើឡើង តាមរយៈវិធីសាស្ត្រការដេញថ្លៃប្រកួតប្រជែងក្នុងស្រុក ក្រោមច្បាប់ និងស្រប តាមបទបញ្ញត្តិលទ្ធកម្មសាធារណៈនៅក្នុងព្រះរាជាណាចក្រកម្ពុជា ។

ក្រសួងអប់រំ យុវជន និងកីឡា បានរៀបចំឯកសារសម្រាប់ក្រុមហ៊ុន/សហគ្រាសបំពេញដើម្បីចូលរួមដេញថ្លៃ និងមានដាក់លក់នៅអង្គភាពលទ្ធកម្មនៃក្រសួងអប់រំ យុវជន និងកីឡា ដែលមានអាសយដ្ឋានអគាររដ្ឋបាលថ្មី(សាលាបឋមសិក្សាចៅពញាហុក)ជាន់ទីពីរ ផ្លូវលេខ៣៨០ សង្កាត់ បឹងកេងកងទី១ ខណ្ឌចំការមន រាជធានីភ្នំពេញ ទូរស័ព្ទ៖ ០២៣ ២១០ ៤៦៤ /០២៣ ២២០ ៩២៧ ទូរស័ព្ទ/ទូរសារលេខ៖០២៣ ២១៥ ២០២ អ៊ីមែល: procurement@moeys.gov.kh គេហទំព័រ www.moeys.gov. kh/procurement ចាប់ពីថ្ងៃទី ០៨ ខែសីហា ឆ្នាំ២០១៩ តទៅ រៀងរាល់ម៉ោងធ្វើការ ។

អ្នកដេញថ្លៃត្រូវកក់ប្រាក់ធានាការដេញថ្លៃ ដែលមានទឹកប្រាក់ចំនួន **៤១ ៧៨០ ០០០រៀល (សែសិបមួយលាន ប្រាំពីររយប៉ែតសិបពាន់រៀលគត់)** ចេញដោយអគ្គនាយកដ្ឋានរតនាគារជាតិ ឬធនាគារពាណិជ្ជដៃគូរណាមួយដែលបានចុះអនុស្សារណៈនៃការយោគយល់គ្នាជាមួយក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ។

កាលបរិច្ឆេទឈប់ទទួលសំណើដេញថ្លៃ នៅវេលាម៉ោង០២:៣០ រសៀលថ្ងៃទី០៦ ខែកញ្ញា ឆ្នាំ២០១៩។

ការបើកសំណើដេញថ្លៃ នឹងប្រព្រឹត្តទៅនៅអង្គភាពលទ្ធកម្ម តាមអាសយដ្ឋានខាងលើនៅវេលាម៉ោង ០២:៣០ រសៀល ថ្ងៃទី ០៦ ខែកញ្ញា ឆ្នាំ២០១៩ ។

ក្រុមហ៊ុន/សហគ្រាស ដែលមានសម្ព័ន្ធភាពជាមួយ ឬមានប្រភពតែមួយ អាចដាក់សំណើដេញថ្លៃបានតែមួយគត់។

ក្រុមហ៊ុន/សហគ្រាសដែលមានបំណងចូលរួមដេញថ្លៃសូមអញ្ជើញទាក់ទងជាមួយអង្គភាពលទ្ធកម្មដើម្បីទិញឯកសារដេញថ្លៃ និងសាកសួរព័ត៌មាន ដែលទាក់ទងនឹងការដេញថ្លៃនេះ ។

បានពិនិត្យត្រឹមត្រូវ

ថ្ងៃ អង្គារ ១៥កើត ខែ អាសាឍ ឆ្នាំកុរ ឯកស័ក ព.ស ២៥៦៣
រាជធានីភ្នំពេញ ថ្ងៃទី ១៦ ខែ កក្កដា ឆ្នាំ២០១៩
**រដ្ឋមន្ត្រីក្រសួងអប់រំ យុវជន និងកីឡា**

បណ្ឌិតសភាចារ្យ **ហង់ជួន ណារ៉ុន**

**ចម្លងជូន៖**
- អគ្គនាយកដ្ឋានលទ្ធកម្មសាធារណៈ
- អង្គភាពប្រឆាំងអំពើពុករលួយ
- កាលប្បវត្តិ
- ឯកសារ អង្គភាពលទ្ធកម្ម